# តើ ខប់សែល ជាអ្វី ?

ខប់សែល ជាអក្សរកាត់នៃពាក្យពេញថា យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ។ នេះជាយន្តការដ៏ពិសេសមួយបានផ្តួចផ្តើមធ្វើនៅកម្ពុជា និងជារបស់កម្ពុជា ហើយដំណើរការដោយវិទ្យាស្ថានបណ្តុះបណ្តាលនិង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) ដែលមានលោក ឱក សេរី សោភក្តិ៍ ជាអ្នកសំរបសំរួល ។



ខប់សែល បង្កើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៩៩ ហើយបានផ្តល់នូវវេទិកាចំហ និងអព្យាក្រឹត សំរាប់ការពិភាក្សាពីបញ្ហាផ្សេងៗទាក់ទិននឹងការបោះឆ្នោត ។ គោលដៅចំបងគឺ ដើម្បីបង្ការទំនាស់ អំពើហិង្សា និងការយល់ច្រឡំពីគ្នាក្នុងដំណើរការបោះឆ្នោត ដោយធ្វើការកសាងទំនុកចិត្ត និងលើកស្ទួយវប្បធម៌សន្ទនាគ្នា ។ តាមរយៈ ខប់សែល វបសអ បានធ្វើការសំរបសំរួលវេទិកាជាច្រើនដែលក្នុងនោះ អ្នកចូលរួមនានាក្នុងការបោះឆ្នោត អាចធ្វើការជាមួយគ្នានៅក្នុងបរិយាកាសមួយដែលបើកចំហ អព្យាក្រឹត និងជាមិត្តភាព ដើម្បីដោះស្រាយក្តីបារម្ភផ្សេងៗក្នុងការបោះឆ្នោត និងដើម្បីស្វះស្វែងរកការឯកភាពគ្នាលើគោលការណ៍រួមនានាសំរាប់ដោះស្រាយការខ្វែងគំនិត ។ តាមរយៈនេះ ខប់សែល ក៏ចូលរួមចំណែកក្នុងការកសាងដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដែលជាលក្ខខណ្ឌត្រូវមានជាមុន ដើម្បីឱ្យរបបប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សអាចរីកលូតលាស់ទៅមុខ ។



ខប់សែល-ដំណាក់កាលទី ១ ដែលដំណើរការពីខែសីហា ១៩៩៩ ដល់ កញ្ញា ២០០៣ បានពាក់ព័ន្ធក្នុងការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០០២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣ ដោយបានជួបប្រជុំប្រចាំខែ ៥០ដង និងទទួលការជួយឧបត្ថម្ភពីមូលនិធិអាស៊ី ។ក្នុងការប្រជុំទាំងនោះ មានការចូលរួមពីតំណាងជាង ១០០នាក់ មកពី រដ្ឋាភិបាល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (NEC) អង្គការមិនមែនរដ្ឋាភិបាល អ្នកឃ្លាំមើលការបោះឆ្នោត ស្ថាប័នរក្សាសន្តិសុខ អង្គការនារី និងគណបក្សនយោបាយនានា ។ កំណត់ហេតុនៃការប្រជុំនីមួយៗបានផ្ញើថ្វាយ និងជូនដល់ព្រះមហាក្សត្រ សមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីទាំងអស់ដែល ពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត អភិបាលនិងអភិបាលរងខេត្ត-ក្រុងទាំងអស់ ស្ថានទូតបរទេស អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិលផ្សេងៗ ។ អង្កេត និងការពិគ្រោះយោបល់នានានៅចុងឆ្នាំ២០០៤ និងដើមឆ្នាំ២០០៥ ជាមួយអ្នកចូលរួមក្នុង ខប់សែល-ដំណាក់កាលទី១ បានចង្អុលបង្ហាញនូវ ប្រសិទ្ធិភាព និងតួនាទីប្រកបដោយលក្ខណៈស្ថាបនារបស់ ខប់សែល ព្រមទាំងមតិគាំទ្រអោយមានដំណើរការ ខប់សែល ជាថ្មីទៀត ។

ខប់សែល-ដំណាក់កាលទី២ ដែលចាប់ផ្តើមនៅខែមិថុនា ២០០៥ ជាប់ពាក់ព័ន្ធជាមួយនឹងការបោះឆ្នោតព្រឹទ្ធសភាឆ្នាំ២០០៦ ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០០៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ ។ ដោយមានជំនួយហិរញ្ញវត្ថុពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ខប់សែល-ដំណាក់កាលទី២ មានដំណើរការរយៈពេល ៣ឆ្នាំ បន្ទាប់ពីការធ្វើសន្និសីទបើកនៅថ្ងៃទី ១៤ កក្កដា ២០០៥ នៅក្រុងភ្នំពេញ ។ ដោយមានបទពិសោធន៍ពី ខប់សែល-ដំណាក់កាលទី១ និងយោងទៅតាមការប្រែប្រួលក្នុងស្ថានភាពខាងសង្គមកិច្ច និងនយោបាយនៅកម្ពុជា ខប់សែល-ដំណាក់កាលទី២ បានរៀបចំឡើងជា ៦ សណ្ឋានៈ

១. សន្និសីទថ្នាក់ជាតិបើកយន្តការថ្ងៃទី ១៤ កក្កដា ២០០៥
២. ខប់សែល ប្រជុំស្នូល (COPCELCOM) ជាមួយជំនាញការខាងបោះឆ្នោតប្រហែល ១៥នាក់






៣. ខប់សែល ប្រជុំទូលាយ (COPCELEM) ជាមួយអ្នកចូលរួមប្រហែល ៥០នាក់
៤. ខប់សែល ប្រជុំថ្នាក់ខេត្ត-ក្រុង (COPCELPROM) ដែលត្រូវមានការប្រជុំ ៤៦លើកយ៉ាងតិច នៅតាមខេត្ត-ក្រុងទាំង២៤ ក្នុងរយៈពេល ៣ឆ្នាំខាងមុខ
៥. ខប់សែល តាមរយៈប្រព័ន្ធផ្សព្វផ្សាយ (COPCELMED) ដែលប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមមធ្យោបាយបោះពុម្ព វិទ្យុ ទូរទស្សន៍ និងអេឡិចត្រូនិក ដើម្បីពិភាក្សាពីបញ្ហាផ្សេងៗ
៦. សន្និសីទថ្នាក់ជាតិបិទយន្តការ នៅពេលចប់ដំណើរការខប់សែល ។

**ខប់សែល គឺជាភស្តុតាងជាក់ស្តែងមួយដ៏សំខាន់នៃការប្តេជ្ញាចិត្តរបស់ វបសអ ដើម្បីធ្វើការងារជាដៃគូជាមួយស្ថាប័ន និងអង្គការកម្ពុជាឯទៀតៗ សំដៅពង្រឹងរបបគ្រប់គ្រងប្រជាធិបតេយ្យនៅកម្ពុជា ។**

ខិតប័ណ្ណផ្សព្វផ្សាយ ខប់សែល-ដំណាក់កាលទី ២ ខែមិថុនា ២០០៦

@ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☞ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រ ៦២២ ភ្នំពេញ ។កម្ពុជា
☎ (855-23) 881-384 /881-701/881-916
🖷 (855-23) 880-734

ខប់សែល-ដំណាក់កាលទី ២ ទទួលជំនួយហិរញ្ញវត្ថុពីកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)

# WHAT IS COPCEL ?

**COPCEL stands for Conflict Prevention in Cambodian Elections. It is a unique Cambodian-initiated and owned mechanism, managed by the Cambodia Development Resource Institute (CDRI), with Mr. Ok SEREI Sopheak as its facilitator.**





Established in mid-1999, COPCEL provides open and neutral forums for the discussion of election-related issues. Its primary objective is to prevent conflict, violence and misunderstanding in elections by building trust and encouraging a culture of dialogue. Through COPCEL, CDRI facilitates forums in which election participants can work together in a friendly, open and neutral environment to address their election concerns and agree on common grounds for settling differences. In a modest way, COPCEL contributes to building free and fair elections, a crucial precondition for democracy and respect for human rights to grow.

COPCEL Phase I, which lasted from August 1999 until September 2003, dealt with the 2002 commune council elections and 2003 national elections. It convened 50 monthly meetings with support from the Asia Foundation. More than 100 representatives from the government, the National Election Committee (NEC), election-monitoring NGOs, security services, women's organisations and political parties participated in the meetings. The minutes of each meeting were sent to the King, all members of the Senate, National Assembly, Constitutional Council and NEC, the Prime Minister, Deputy Prime Ministers, all ministers involved in the conduct of elections, all provincial governors and deputy governors, foreign embassies and other international and civil society organisations. Surveys and consultations in late 2004 and early 2005 with participants of COPCEL Phase I confirmed the effectiveness and constructive role of COPCEL, and strongly recommended its renewal.

COPCEL Phase II, which began in June 2005, deals with the 2006 Senate elections, 2007 commune council elections and 2008 national elections. With financial support from the United Nations Development Programme, COPCEL Phase II will run for three years following its launching conference in Phnom Penh on 14 July 2005. Having learned from the experience of Phase I, and taking into consideration Cambodia's changing social and political circumstances, COPCEL Phase II is designed around six structures:

1. Launching Conference, 14 July 2005.
2. COPCEL Core Meeting (COPCELCOM), monthly, with about 15 election experts.
3. COPCEL Enlarged Meeting (COPCELEM), quarterly, with about 50 participants.






4. COPCEL Provincial Meeting (COPCELPROM), at least 46 meetings in all 24 provinces/municipalities during the next three years.
5. COPCEL Media (COPCELMED), using print and electronic media to discuss issues.
6. Closing Conference, at the conclusion of the process.

**COPCEL is an important expression of CDRI's commitment to working in partnership with other Cambodian institutions and organisations to deepen democratic governance in Cambodia.**

**COPCEL-II FLYER, June 2006**


@ Cambodia Development Resource Institute

☞ 56, Street 315, Tuol Kork

✉ PO Box 622 Phnom Penh, Cambodia

☎ (855-23) 881-384/881-701/881-916/883-603

🖷 (855-23) 880-734


COPCEL Phase II is financially supported by the United Nations Development Programme (UNDP)